



| បញ្ជីអត្ថបទ | ទំព័រ |
|---|---|
| ១. អ្នករងគ្រោះ ពិតប្រាកដ នៅ ឃុំ ដាក់ដាំ (Real Victims in Dak Dam Commune, p. 1) | … ១ |
| ២. មនុស្ស ខូច ឆ្លៀត ឱកាស (Opportunists, p. 3) | … ៣ |


## អ្នក រងគ្រោះ ពិតប្រាកដ

ក្នុង ខែ មេសា នេះ ការប្រជុំ មួយ បាន រៀបចំឡើង នៅ ឃុំ ដាក់ដាំ រវាង ប្រជាជន, អាជ្ញាធរ មូលដ្ឋាន គ្រប់ជាន់ថ្នាក់ និង តំណាង ក្រុមហ៊ុន ដាំដើមស្រល់ ដើម្បី ស្វែងរក ដំណោះស្រាយ ដែលទាក់ទងទៅនឹង ការធ្វើ អាជីវកម្ម ចំការស្រល់ ។ កិច្ចប្រជុំ នោះ មាន អ្នកចូលរួម ប្រមាណ ៦០ នាក់ ។

មជ្ឈដ្ឋាន សាធារណ: តែងតែ បានគិតថា ជនរងគ្រោះ នៃ ការបាត់បង់ ដីធ្លី ដោយសារ ការធ្វើ ចំការ ដើមស្រល់ នៅ ឃុំ ដាក់ដាំ ដោយ ក្រុមហ៊ុន តៃវ៉ាន់ សុទ្ធតែ ជា ប្រជាជន មូលដ្ឋាន ដែល ភាគច្រើន ជា ជនជាតិដើមភាគតិច ។ ប៉ុន្តែ ការពិត មិនដូច្នោះ ឡើយ ។

ក្រុម បុគ្គលិក របស់ អេប៊ិក (ABiC) ដែលធ្វើ ប្រតិបត្តិការ ការងារ របស់ ខ្លួន ជាអាលជ្ជី នៅក្នុង ឃុំ ដាក់ដាំ បានដឹងថា ដីធ្លី ដែលកំពុង ឈូសឆាយ ដោយក្រុមហ៊ុន វិនិយោគ ចំការស្រល់ ហាក់បីដូចជា មិនទាន់ ប៉ះពាល់ ដល់ ដីធ្លី របស់ ប្រជាជន ជនជាតិដើម ភាគតិច (ភ្នង) នៅ ឃុំ ដាក់ដាំ ឡើយ ។

ការពិគ្រោះយោបល់ ជាមួយ ប្រជាជន ជនជាតិដើម ភាគតិច និង ចាស់ទុំ នៅ ឃុំ ដាក់ដាំ បានឱ្យដឹងថា ដីធ្លី ដែល ក្រុមហ៊ុន កំពុង ឈូសឆាយ ក្នុង ខែ មេសា នេះ ពុំមាន ប៉ះពាល់ ដល់ ដីធ្លី ដែល ពួកគាត់ ធ្លាប់បាន និង កំពុង ប្រើប្រាស់ ឡើយ ។ មានដីធ្លី របស់ គ្រួសារ ប្រជាជន ជនជាតិដើម ភាគតិច ពីរ គ្រួសារ ដែល ប៉ះពាល់ ។ ប៉ុន្តែ ដីធ្លី នោះ

គឺជា ដីធ្លី ដែល ពីដើមរៀងមក ប្រជាជន មិនធ្លាប់ ប្រើប្រាស់ សោះ ។ គ្រួសារ ទាំងពីរនោះ បានវាទរបងព័ទ្ធ យកដីនោះ ក្នុងពេល ថ្មីៗនេះ សម្រាប់ទុកលក់ ជាប្រយោជន៍ គ្រួសារ របស់ខ្លួន តែប៉ុណ្ណោះ ។

បីគ្រួសារទៀត ដែលប៉ះពាល់ ដែរនោះ គឺជា ប្រជាជន ចំណូលថ្មី ដែលទើបតែមកតាំងទីលំនៅ និង ចាប់យក ដីធ្លី នៅក្នុង ឃុំ ដាក់ដាំ ។ គ្រួសារ ដ៏ទៃទៀត ដែល ទទួលរង ការប៉ះពាល់ ដីធ្លី នោះ គឺជា គ្រួសារ ដែល រស់នៅ ក្នុង ទីរួមខេត្ត មណ្ឌលគិរី និង មកពី ភ្នំពេញ ដែល បានវាទរបងព័ទ្ធយក ដីធ្លី ទាំងនោះ សម្រាប់ លក់ដូរ តែប៉ុណ្ណោះ ។ ហេតុនេះ យើង អាច និយាយ បានថា គ្រួសារ ដែល រង ការប៉ះពាល់នេះ គឺជា គ្រួសារ ដែលមាន មហិច្ឆតា មិនល្អ ដោយ គិត តែ ប្រយោជន៍ បុគ្គល-គ្រួសារ ដែល បានយក ដីធ្លី របស់រដ្ឋ មកកាន់កាប់ ពុំមាន ទាំងកម្មសិទ្ធិ ស្របច្បាប់ ទៀតផង ។

ចាស់ទុំ មូលដ្ឋាន និង ប្រជាជន ជនជាតិដើម ភាគតិច នៅ ឃុំ ដាក់ដាំ ពុំបាន ព្រួយបារម្ភ អំពី បញ្ហា គ្រួសារ-បុគ្គល ទាំងនេះ ឡើយ ។ ពួកគាត់ គិតថា ប្រសិនបើ ក្រុមហ៊ុន ដំណើរការ បង្កើតបាន ជា ការងារ សម្រាប់ ឱ្យពួកគាត់ បានចិញ្ចឹមជីវិត និង មាន ផែនទី បញ្ជាក់ពី វិសាលភាព ចំការ ដើមស្រល់ ឱ្យបាន ច្បាស់លាស់ មិនប៉ះពាល់ ដល់ តំបន់ ដាំដុះ, វាលស្មៅ ចិញ្ចឹម សត្វ, ព្រៃ

**Real Victims in Dak Dam Commune**

An ad hoc meeting was called between the Taiwanese Pine Plantations Company and local authorities and local communities in late April after the company bulldozed land for its plantations in Dak Dam commune. It was believed that the victims of the land bulldozed are indigenous people – Phnong – of Dak Dam commune. It turns out to be untrue.

ABiC staff members who are working with Dak Dam's indigenous people did an investigation right away with the participants of the meeting, Dak Dam's indigenous groups and elders. Indigenous people who were participants and non-participants of the meeting and Phnong elders reported that there were nearly none of their community members were victims of the land the company was preparing for the plantations.

Two of the indigenous families would lose the land they fenced up for speculation. They recently took the land, which was never used by local people at all, with the hope that they could trade it for cash. Three other families – all new settlers from low land areas – who would lose their land came to settle in Dak Dam just recently. They grabbed land, which was never used by the community, for speculation too. The other victims who would lose the land are all but land speculators from Sen Monorom town and Phnom Penh. ABiC does not and will never support the effort of these people. However, ABiC supports and will support the real victims.

Dak Dam community people and elders will be happiest if the company could create job for them to improve their life, and have clear demarcation of areas needed for the company's plantations that will not affect their residential and cultivation areas, grazing land, sacred forest and burial sites. This is worth considering by all concerned.

អារក្ស និង ព្រៃ កប់ខ្មោច របស់ សហគមន៍ គាត់ នោះ ទើបជាអ្វី ដែល ពួកគាត់ ចង់បាន ។ បើមិន ដូច្នោះទេ ពួកគាត់ ពិតជា មាន ការមិននឹងនរ ក្នុង ចិត្ត ឡើយ ។ បែបនេះ អាច ធ្វើឱ្យ ក្រុម ខិលខូច ឆ្លៀតឱកាស ញុះញង់ ពួកគាត់ ឱ្យបង្កបាតុភូត សង្គម ផ្សេងៗ ដែល អាចធ្វើឱ្យ ស្ថានការណ៍ មិន អាច គ្រប់គ្រង បាន ។

អេប៊ិក មិនគាំទ្រ ជាដាច់ខាត នូវ បុគ្គល-គ្រួសារ និង ក្រុម ខិលខូច ដែល ឆ្លៀតឱកាស កេងយក ផលប្រយោជន៍ របស់ ប្រជាជន ស្លូតត្រង់ ឬ ញុះញង់ ឱ្យ ពួកគាត់ បង្ក បញ្ហា ដើម្បី ដើម្បី ជា ប្រយោជន៍ បុគ្គល-គ្រួសារ ។ អេប៊ិក គាំទ្រ តែ ទង្វើ ដែល ត្រឹមត្រូវ តាមច្បាប់ ជាតិ និង ច្បាប់ អន្តរជាតិ ដែល ប្រទេស កម្ពុជា ជា ហត្ថលេខី ហើយ អេប៊ិក ការពារ តែ ផលប្រយោជន៍ របស់ ប្រជាជន ស្លូតត្រង់ ពិតប្រាកដ តែប៉ុណ្ណោះ ។

**Opportunists**

With support from a local NGO Snuol Community Forest Network was prepared to re-elect its committee members at all levels in late April. While busy with the re-election activities their forest and land patrol efforts became limited and no mechanism was put in place, during this period, to watch and deter the illegal land grabbers and loggers. As a result some vulnerable areas were being encroached and a significant area of land was cleared and taken, for example, in Trapean Leakh village.

This really reflects how fruitful effort could be easily obliterated in the face of the lack of the rule of law. Without the rule of law, all good achievements cannot be sustainable and can be perished quickly.

What does the rule of law mean? A country with the rule of law is a country in which law exists, every citizen learns and respects the law, judicial system is independent and practices the law strictly, and impunity is never tolerated. Cambodia has some law, but awareness of and respect for law is limited, judicial system is not totally independent and [sometimes] does not abide by the law, and impunity remains a major problem.

The effort of the Royal Government of Cambodia in legal and judicial reform, as cast in the Rectangular Strategy (2004), that will address these issues should be strongly supported and must be accelerated.

## មនុស្ស ខូច ឆ្លៀត ឱកាស

កុក តែងតែ ភ្លេច ជង់ តែ ជង់ មិន ចេះ ភ្លេច កុក ទេ ។ ជន ស្លូតត្រង់ ពេល បាន សេចក្ដីសុខ តែងតែ ភ្លេច ត្រចៀក ។ នេះ គឺជា ឱកាស ល្អ សម្រាប់ ជន ខិលខូច ។

ដោយ មាន ការជួយ ឧបត្ថម្ភ ពី អង្គការ មិនមែន រដ្ឋាភិបាល, នា ចុង ខែ មេសា នេះ បណ្ដាញ សហគមន៍ ព្រៃឈើ ស្រុក ស្នួល ត្រូវ បាន ត្រៀមរៀបចំ និង បោះឆ្នោត ជ្រើសរើស តំណាង របស់ ខ្លួន ជាថ្មីឡើងវិញ តាំងពី ថ្នាក់ ឃុំ រហូតដល់ ថ្នាក់ ស្រុក ។ ក្នុង រយៈពេល រៀបចំ ជ្រើសរើស តំណាង

ឡើងវិញ នេះ ការងារ ល្បាត ព្រៃឈើ និង ដីធ្លី មានសភាព ខិនថយ និង អសកម្ម មួយ រយៈ ។ ស្ថានការណ៍ នេះ បានផ្តល់ ឱកាស មាស ដល់ ជន ខិលខូច ។

ដោយ គ្មាន យន្តការ បម្រុង ទប់ទល់ នឹង ជនឆក់ឱកាស និង ដោយ កំពុង ជាប់ដៃ រវល់ ក្នុង ការរៀបចំ ជ្រើសរើស តំណាងថ្មី, ភូមិ មួយចំនួន ដែល ងាយរងគ្រោះ ត្រូវបាន ជន ខិលខូច កាប់ទន្ទ្រាន យក ដីព្រៃ អស់មួយសន្ធឹក ។ ឧទាហរណ៍ នៅ ភូមិ ត្រពាំងលក្ខណ៍ ជន ខិលខូច បាន ឆ្លៀតឱកាស កាប់ទន្ទ្រាន យក ដីព្រៃ អស់ ជាច្រើន ហិកតា ។

លុះត្រាតែ មាន នីតិរដ្ឋ កិច្ចខិតខំប្រឹងប្រែង ទាំងអស់ នឹង ពុំទទួលបាន លទ្ធផល ចីរភាព ហើយ ក៏ នឹង ក្លាយជា អសារឥតការ ជាមិនខាន ។ ប្រទេស មាន នីតិរដ្ឋ ជា ប្រទេស ដែល មាន ច្បាប់, ប្រជាពលរដ្ឋ គ្រប់រូប ចេះដឹង និង គោរព ច្បាប់, ប្រព័ន្ធ តុលាការ មាន ឯករាជ្យ និង ប្រតិបត្តិ តាមគន្លង នៃ ច្បាប់ ព្រមទាំង គ្មាន វប្បធម៌ និរទណ្ឌភាព ។

បច្ចុប្បន្ន ប្រទេស កម្ពុជា មាន ច្បាប់ មួយ ចំនួន បើទោះ ជា ពុំទាន់ គ្រប់គ្រាន់ ក្តី ។ ប៉ុន្តែ ការយល់ដឹង និង ការគោរព ច្បាប់ នៅមាន កម្រិត, បញ្ហា និរទណ្ឌភាព នៅតែ មាន ហើយ តុលាការ ក៏ ខ្វះឯករាជ្យភាព ព្រមទាំង ពេលខ្លះ បំពាន ច្បាប់ ទៀតផង ។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែង របស់ រាជរដ្ឋាភិបាល ក្នុង ការកែទម្រង់ វិស័យ ច្បាប់ និង វិស័យ តុលាការ ត្រូវតែ ទទួល បាន នូវ ការគាំទ្រ យ៉ាងពេញទំហឹង និង ជំរុញ ឱ្យកាន់តែ បានលឿន ថែមទៀត ។

"រាជរដ្ឋាភិបាល ខិតខំ ជម្រុញ ការកែ ប្រព័ន្ធ ច្បាប់ និង តុលាការ ឱ្យបាន ឯករាជ្យ ... ក្នុង គោលដៅ ពង្រឹង នីតិរដ្ឋ, បង្កើន យុត្តិធម៌ នៅក្នុង សង្គម, កាត់បន្ថយ អំពើ ពុករលួយ, ឈានទៅ លុបបំបាត់ វប្បធម៌ និរទណ្ឌភាព ព្រមទាំង ពង្រឹង វប្បធម៌ សន្តិភាព និង វប្បធម៌ នៃ ការគោរពច្បាប់ ។ ..." (យុទ្ធសាស្ត្រ ចតុកោណ របស់ រាជរដ្ឋាភិបាល កម្ពុជា, ២០០៤) ។

